KINGDOM OF CAMBODIA
Nation Religion King

Permanent Mission of the Kingdom of Cambodia
to the United Nations Office and other
International Organizations in Geneva

No: 2024/12/699

The Permanent Mission of the Kingdom of Cambodia to the United Nations Office and other International Organizations in Geneva presents its compliments to the United Nations Human Rights Office of the High Commissioner and, with reference to the latter's Joint Communication No. AL KHM 1/2024 dated 17 October 2024, has the honour to attach Cambodia's response to the inquiries of the Special Rapporteurs in the Joint Communication regarding the resettlement of Angkor inhabitants.

The Permanent Mission would appreciate it if the aforementioned document would be conveyed to its highest destination.

The Permanent Mission of the Kingdom of Cambodia to the United Nations Office and other International Organizations in Geneva avails itself of this opportunity to renew to the United Nations Human Rights Office of the High Commissioner the assurances of its highest consideration.

Geneva, 17 December 2024

United Nations Human Rights
Office of the High Commissioner

**Geneva**

Address: 3 Chemin Taverney, P.O. Box 213
1218 Grand-Saconnex, Geneva, Switzerland
Tel : (41) 22 788 77 73
E-mail : camemb.gva@mfaic.gov.kh

# Cambodia's Clarifications to the Inquiries by Special Rapporteurs on the Resettlement of the Angkor Inhabitants

1. Please provide any additional information and/or comment(s) you may have on the above-mentioned allegations.

   - The Royal Government of Cambodia respects the human rights principles by striving to provide decent housing to poor families across the country to obtain proper housing and a better life through the Social Land Concession Programme. So far, the Social Land Concession Project has been implemented in 18 provinces, providing a total of 1,356,752 hectares of land to 487,457 families, and constructing 8,141 houses, including housing arrangements for voluntary residents who do not have legal housing and land in the Angkor site to resettle in Runta Ek Techo Sen city and the Paek Sneng development area in the Banteay Srei district of Siem Reap province. All residents who voluntarily resettle in the newly arranged settlements obtained legal land titles and access to infrastructure, roads, schools, health centers, pagodas, markets and public services.
   - The purported news saying there were violations of citizens' rights through forced relocation from the Angkor area to the cities of Run Ta Ek Techo Sen and the development area of Paek Sneng is distorted information beyond the truth, fabricated by a handful of ill-intent group with the aim of political incitation, causing civil unrest, hostility, public order and spiritual peace, leading to the destruction of the economy and livelihoods of the people living in the areas of Run Ta Ek and Paek Sneng, as well as the Angkor World Heritage Site.

2. Please provide information about the mechanisms in place to ensure the right of the individuals, including Indigenous Peoples, concerned to fully participate in decision-making processes that affect their cultural life, including their participation in the governance and management of the site of Angkor and their representation in the Authority for the Protection of the Site and Management of the Region of Angkor (APSARA).

   - The Royal Government has set out a number of policies and mechanisms to support people who voluntarily relocate from the Angkor World Heritage Site to a new settlement in Run Ta Ek Techo Sen and Paek Sneng development area to protect the Angkor World heritage site, and improve the lives of the people, in accordance with the Constitution of the Kingdom of Cambodia, laws and regulations, including:
     - Sub-Decree No. 155, dated July 26, 2022, on the Land Reclamation of 81.5 Hectares, located in Tani Village, Run Ta Ek Commune, Banteay Srei District, Siem Reap Province, to prepare the infrastructure of parks, roads, and provision to the people;

- Sub-Decree No. 130 dated June 16, 2023 on the Land Reclamation of 964 Hectares 96A in Tani Village, Run Ta Ek Commune, Banteay Srei District, Siem Reap Province for provision to people who meet the conditions and volunteer to leave the Angkor area;
- Sub-Decree No. 40 dated February 22, 2024 on the Implementation of the Rehabilitation Programme for the Relocation of Residents to Run Ta Ek Techo Sen and Paek Sneng Commune of Angkor Thom District, Siem Reap Province;
- Decision No. 26 dated April 18, 2022 on the Establishment of an Orientation Working Group to Address Illegal Construction and Land in Angkor Resort and Other Areas Under the Management of APSARA Authority;
- Decision No. 241 dated December 22, 2023 on the appointment of the composition of the inter-ministerial commission to organize the town of Run Ta Ek and Paek Sneng in Siem Reap;
- Decision No. 063 of the Ministry of Land Management, Urban Planning and Construction, dated August 09, 2022 on the establishment of a technical working group to identify people who have built and occupied land in the Angkor area and other areas under the management of APSARA Authority;
- Letter No. 998 of the Council of Ministers dated October 9, 2023 deciding in principle to continue to encourage people to relocate from the Angkor area to the Run Ta Ek development area and Paek Sneng as a settlement with proper infrastructure, including roads, water, electricity, schools and local markets, based on the spirit of transforming the area into a location that supports Siem Reap's priority tourism development policy, tourism investment, and the development of new tourism corridors, heritage and nature tourism, promotion of the development of model villages, continuing to promote on-site export policies and strengthening support services to uphold the rehabilitation and development process of Siem Reap and Angkor International Airport;
- Decision No. 042, dated March 18, 2023 on the Establishment of a Working Group to Facilitate the Departure of People from the Angkor Area and Resettlement in the Run Ta Ek Development Zone and Paek Sneng Development Area;
- Decision No. 139, dated October 25, 2023, on the Establishment of the Inter-Ministerial Commission for the Development of Run Ta Ek and Paek Sneng Towns in Siem Reap Province.

▪ In carrying out these necessary tasks, the line ministries, institutions and local authorities at all levels strive to coordinate with the people involved by maximally adhering to the principles of human rights and humanitarian

compassion, including holding of several meetings to disseminate and explaining these crucial quests of the Royal Government, which in return overwhelming amount of people much appreciate and are happy to accept the Royal Government's solution.

3. Please provide information on the measures taken to clearly identify the 113 “traditional villages”, and any private or community-owned land, which should not be subjected to evictions, and to provide these individuals including Indigenous Peoples with legal security of tenure. In addition, please indicate how has your Excellency's Government endeavoured to ensure that all people living in Angkor can enjoy a certain degree of security of tenure.

    - After Angkor Wat was registered as a World Heritage Site in 1992, the Apsara National Authority, in 2004, conducted a census of villagers in all the villages within the Angkor area to serve as a baseline for the management of the site and measures to protect Angkor residents. The residents on the 2004 list are considered to be legally settled residents and are granted full protection and other assistance by the state for contributing to the protection of the heritage of humanity. At present, the number of people who have settled in an irregular manner in the heritage protection area without adequate infrastructure to support their lives has increased significantly, imposing a serious pressure on the ancient temples and the surrounding environment. Since these residents do not have legal land ownership and access to clean water, electricity, roads, sewage systems, hospitals and schools, the Royal Government urgently needs to come up with appropriate solutions.
    - The Royal Government has provided 5,865 plots of land in Runta Ek Techo Sen and 4,039 in the Paek Sneng Development Area to families willing to resettle. However, this can only accommodate 9,904 families of those who are illegally settling in the Angkor site area. There are still a number of families that the Royal Government needs to accommodate.
    - The Angkor residents are not indigenous people, but they are Cambodian citizens who have resided in the Angkor Archaeological Park area for a long time before 2004, and they are considered part of the living heritage, the soul of the temples, which have received state support and encouragement.

4. Please provide information on the measures that your Excellency's Government is undertaking to protect the communities living in Angkor from forced evictions and arbitrary displacement; and to ensure that any decision affecting Indigenous Peoples' lands, territories and resources is taken only with their free, prior and informed consent.

- The Royal Government has set out many laws, policies and legal regulations, including Royal Decree No. 001 N.S. dated May 18, 1994 on the designation and management of the Siem Reap Angkor area and Decision No. 70 S.S. dated November 16, 2004 on the designation of land use standards for Zone 1 and Zone 2 in the Siem Reap Angkor area, etc., in accordance with applicable laws, especially the Constitution of the Kingdom of Cambodia, which is the supreme law of the nation. Through these regulations, the rights of Angkor residents are protected as follows:
  - Residents who have lived and resided in their homes for a long time can continue to live there without being evicted.
  - Residents have the rights to demolish and repair old dilapidated houses or build new ones to replace old houses with a permission from the Apsara National Authority.
  - Residents have the rights to own and manage land in various ways such as transferring inheritance to relatives, from parents to children, or sale to villagers to support their livelihoods, but it is prohibited to buy and sell land by merchants with the aim of making a profit for companies or individuals, or to buy and sell land for the construction of hotels, restaurants, or entertainment venues, etc.
  - Residents living in the Angkor area have the priority right to work in the conservation and restoration of temples, as well as receive professional training related to the conservation and management of Angkor sites.
  - The state is to find possibilities of creating tourism communities for local people to generate daily income from tourism.
  - Encourage the organization of cultural communities in villages to preserve and indicate the traditions of ancestors to descendants.
  - Promote the value of landscapes through land management, environmental management systems, and nature conservation plans in the Angkor heritage protection area.

5. Please indicate whether all people threatened with or already subjected to forced resettlement have been meaningfully consulted, have had the possibility to propose alternatives to resettlement, to participate in the selection of the resettlement sites, in defining adequate compensation including replacement land, as well as integration measures. Please also indicate how your Excellency's Government has obtained the free, prior and informed consent of the Indigenous Peoples for the resettlement plan.

   - People listed in the 2004 census are not being relocated unless they apply for new housing with complete land ownership and structure in the Runta Ek Techo Sen and Paek Sneng Development Area, and the Royal Government continues to accept applications and facilitate the provision

of housing to them based on humanitarian principle. However, those who have settled illegally in the Angkor National Park Protection Area do not own any land or buildings. Most of them live in shacks or huts in a slum-like environment without safety and comfort. Therefore, they are happy and willing to accept the solutions provided by the Royal Government.

6. Please provide information on the efforts that your Excellency's Government is undertaking to ensure that the resettled communities resume and continue enjoying access to adequate housing, food, land for food production, safe drinking water and sanitation, and other means of livelihood.

The Royal Government will continue to implement the following priorities:

- Continue to urge relevant ministries and institutions to set these tasks as their highest priority to ensure that schools, health centres and other public buildings in the new area have adequate and reliable facilities, staffs and public servants,
- Continue to encourage residents who have already been selected but have not yet left to move to new homes in these two development areas in a timely manner, and for the authorities to prevent further encroachment in areas that have already been relocated,
- Encourage the private sector to establish business, production and service bases in and around these two development areas to create additional job opportunities and occupations for residents in both areas, and transform them into satellite cities with vibrant economic activities, drawing maximum advantages of the economic potential of the tourism sector arising from Angkor and other ancient temples, and infrastructure development projects for roads, economic zones, boreys, residence and Siem Reap Angkor International Airport, etc.
- Promote land registration and issuance of title deeds to residents in these two areas as a top priority to ensure the security of possession and use of real estates with confidence and legality, and opportunities to build a better economy.
- Promote further development of Runta Ek Techo Sen and the surrounding areas by setting up a comprehensive package for the effective and interconnected management of physical infrastructure, socio-economic infrastructure, and public services to transform them into a model area for the implementation of the state's social land concession project into "The first Contemporary Rural Borey in Cambodia."

7. Please indicate the steps that your Excellency's Government has taken to ensure that relocation complies with international human rights standards, as requested in decision 46 COM 7B.31 issued during the 46th session of the World Heritage Committee. Additionally, please indicate whether your Excellency's Government

has invited a Reactive Monitoring Mission to assess among other things the conditions of the relocated communities, as required under the decision, and provide information on the Reactive Monitoring Mission's scope and possible dates.

- The Cambodian authorities did not take any coercive measures to force people to leave the Angkor site, other than on a voluntary basis. Some of the negative news that has emerged from the implementation of measures by the Cambodian authorities against squatters who have illegally occupied land and settled in the Angkor site area is a common measure that is often taken by competent authorities in all countries around the world.
- The Cambodian authorities welcome all parties, including international organizations, who are interested in promoting the protection of Angkor heritage and respect for human rights, to join the process the Royal Government of Cambodia is implementing to improve housing, infrastructure, public services and livelihoods of the people of Runta Ek Techo Sen and the Paek Sneng Development Area, as well as throughout the country, aiming to achieve the vision of the Royal Government of Cambodia to transform all villages into the village of peace, security, sustainability, social harmony and happiness.

8. Please indicate what measures have been taken to ensure that persons, including Indigenous Peoples, who have lost their housing, land, property, means for food production or livelihoods, or who have suffered any economic or cultural effect as a result of the forced evictions, arbitrary displacement and forced resettlement, have access to effective remedy and reparation.

    - As indicated in Answer 6.

9. Please clarify what measures have been taken or are envisaged to provide protection and assistance to those displaced in Angkor, including the steps taken to ensure access to justice for victims and accountability for perpetrators of arbitrary displacement and attacks on displaced persons. Also, please provide information on any steps taken to enable durable solutions to their displacement.

    - As indicated in Answer 7.

## ជំនួយស្មារតីពាក់ព័ន្ធនឹងសំណួរ និងការលើកឡើងរបស់ក្រុមអ្នករាយការណ៍សិទ្ធិមនុស្ស ស្តីពីការផ្លាស់ទីលំនៅថ្មីរបស់ប្រជាពលរដ្ឋពីតំបន់រមណីយដ្ឋានអង្គរ ទៅកាន់ក្រុងរុនតាឯកតេជោសែន និងតំបន់អភិវឌ្ឍន៍ពាក់ស្នែង

១- Please provide any additional information and/or comment(s) you may have on the above-mentioned allegations.

- រាជរដ្ឋាភិបាលកម្ពុជា គោរពគោលការណ៍សិទ្ធិមនុស្ស ដោយខិតខំផ្តល់ជូននូវលំនៅឋានសមរម្យដល់គ្រួសារក្រីក្រនៅទូទាំងប្រទេស ដើម្បីទទួលបានផ្ទះសម្បែងសមរម្យ និងជីវភាពល្អប្រសើរ តាមរយៈកម្មវិធីផ្តល់ដីសម្បទានសង្គមកិច្ច។ រហូតមកដល់ពេលនេះ គម្រោងដីសម្បទានសង្គមកិច្ចអនុវត្តបាន ក្នុង ១៨ខេត្ត ផ្តល់ដីសរុប ១ ៣៥៦ ៧៥២ហិកតា ដល់គ្រួសារចំនួន ៤៨៧ ៤៥៧គ្រួសារ និងសាងសង់ផ្ទះចំនួន ៨ ១៤១ខ្នង ក្នុងនោះ រាប់ទាំងការរៀបចំលំនៅឋានជូនប្រជាពលរដ្ឋស្ម័គ្រចិត្ត ដែលគ្មានលំនៅឋាននិងដីធ្លីស្របច្បាប់នៅក្នុងតំបន់រមណីយដ្ឋានអង្គរ ទៅតាំងទីលំនៅថ្មីនៅក្នុងក្រុងរុនតាឯកតេជោសែន និងតំបន់អភិវឌ្ឍន៍ពាក់ស្នែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ ប្រជាជនគ្រប់រូបដែលស្ម័គ្រចិត្តតាំងទីលំនៅថ្មីដែលយើងបានរៀបចំ ទទួលបានបណ្ណកម្មសិទ្ធិដីធ្លីស្របច្បាប់ ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ សាលារៀន មណ្ឌលសុខភាព វត្តអារាម ផ្សារ និងសេវាសាធារណៈ។
- ព័ត៌មានដែលថា មានការរំលោភសិទ្ធិប្រជាពលរដ្ឋ តាមរយៈការរុះរើដោយបង្ខំពីតំបន់អង្គរទៅកាន់ក្រុងរុនតាឯកតេជោសែន និងតំបន់អភិវឌ្ឍន៍ពាក់ស្នែង គឺជាព័ត៌មានបំភ្លៃបំប៉ោងលើសពីការពិត ដែលត្រូវបានបង្កើតឡើងដោយក្រុមអគតិមួយក្តាប់តូច ក្នុងចេតនាញុះញង់ផ្នែកនយោបាយ បង្កឱ្យមានអរិយភាព ភាពប្រទូស្តរាយ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិភាពផ្លូវចិត្ត ឈានទៅបំផ្លិចបំផ្លាញសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលកំពុងរស់នៅតំបន់រុនតាឯក និងពាក់ស្នែង ក៏ដូចជាតំបន់បេតិកភណ្ឌពិភពលោកអង្គរ។

២- Please provide information about the mechanisms in place to ensure the right of the individuals, including Indigenous Peoples, concerned to fully participate in decision-making processes that affect their cultural life, including their participation in the governance and management of the site of Angkor and their representation in the Authority for the Protection of the Site and Management of the Region of Angkor (APSARA).

- រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ និងយន្តការជាច្រើន ដើម្បីទទួលយកប្រជាពលរដ្ឋដែលស្ម័គ្រចិត្តប្តូរទីលំនៅចេញពីតំបន់រមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ ទៅតាំងទីលំនៅថ្មី នៅក្រុងរុនតាឯកតេជោសែន និងតំបន់អភិវឌ្ឍន៍ពាក់ស្នែង សំដៅការពាររមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ និងលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋឱ្យប្រសើរជាងមុន ស្របតាមស្មារតីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្នុងនោះ រួមមានជាអាទិ៍÷

១. អនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការធ្វើអនុបយោគដីទំហំ ៨១,៥ហិកតា មានទីតាំង ស្ថិតនៅភូមិតានី ឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ សួន បឹង និងធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ

២. អនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការធ្វើអនុបយោគដីទំហំ ៩៦៤ហិកតា៩៦អា ស្ថិតនៅភូមិតានី ឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប ជាដីឯកជនរបស់រដ្ឋ និងចុះបញ្ជីជូនអាជ្ញាធរជាតិអប្សរា សម្រាប់ធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ ដែលគ្រប់លក្ខខណ្ឌ និងស្ម័គ្រចិត្តចាកចេញពីតំបន់រមណីយដ្ឋានអង្គរ

៣. អនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការអនុវត្តកម្មវិធីស្តារជីវភាពឡើងវិញ សម្រាប់ការផ្លាស់ប្តូរលំនៅឋានរបស់ប្រជាជនទៅក្រុងរុនតាឯកតេជោសែន និងឃុំពាក់ស្នែងនៃស្រុកអង្គរធំ ខេត្តសៀមរាប

៤. សេចក្តីសម្រេចលេខ ២៦ សសរ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ ស្តីពីការបង្កើតក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់ និងដីធ្លី ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា

៥. សេចក្តីសម្រេចលេខ ២៤១ សសរ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំទីប្រជុំជនរុនតាឯក និងទីប្រជុំជនពាក់ស្នែង ខេត្តសៀមរាប

៦. សេចក្តីសម្រេចលេខ ០៦៣ សសរ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២២ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេស ចុះធ្វើអត្តសញ្ញាណប្រជាពលរដ្ឋដែលបានសាងសង់ និងកាន់កាប់ដីធ្លី ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ដើម្បីធ្វើអត្តសញ្ញាណប្រជាពលរដ្ឋដែលបានសាងសង់ និងកាន់កាប់ដីធ្លី

៧. លិខិតលេខ ៩៩៨ សជណ ជប ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០២៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី បានសម្រេចជាគោលការណ៍ ឱ្យបន្តលើកទឹកចិត្តឱ្យប្រជាពលរដ្ឋចាកចេញពីតំបន់រមណីយដ្ឋានអង្គរទៅតាំងទីលំនៅថ្មី នៅតំបន់អភិវឌ្ឍន៍រុនតាឯក និងពាក់ស្នែង ជាកន្លែងដែលមានហេដ្ឋារចនាសម្ព័ន្ធសមស្របរួមមាន ផ្លូវ ទឹក ភ្លើង សាលារៀន និងផ្សារ លើមូលដ្ឋានប្រែក្លាយតំបន់នេះឱ្យទៅជាទីតាំងដែលគាំទ្រដល់គោលនយោបាយនៃការអភិវឌ្ឍតំបន់ទេសចរណ៍អាទិភាព ខេត្តសៀមរាប ការវិនិយោគទេសចរណ៍ និងអភិវឌ្ឍរបៀងទេសចរណ៍ថ្មីៗ ជាទេសចរណ៍បេតិកភណ្ឌ និងធម្មជាតិ ការជំរុញអភិវឌ្ឍភូមិឋានគំរូ ការបន្តលើកកម្ពស់គោលនយោបាយនាំចេញនៅនឹងកន្លែង និងការពង្រឹងការតភ្ជាប់សេវាគាំទ្រនានា សំដៅជំរុញការស្តារ និងដំណើរការអភិវឌ្ឍខេត្តសៀមរាប និងអាកាសយានដ្ឋានអន្តរជាតិអង្គរ

៨. សេចក្តីសម្រេចលេខ ០៤២ សសរ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ ស្តីពីការបបង្កើតក្រុមការងារសម្របសម្រួល ការចាកចេញរបស់ប្រជាពលរដ្ឋចេញពីតំបន់រមណីយដ្ឋានអង្គរ និងការតាំងទីលំនៅថ្មីនៅតំបន់អភិវឌ្ឍរុនតាឯក និងតំបន់អភិវឌ្ឍពាក់ស្នែង

៩. សេចក្តីសម្រេចលេខ ១៣៩ សសរ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំការអភិវឌ្ឍទីប្រជុំជនរុនតាឯក និងទីប្រជុំជនពាក់ស្នែង ខេត្តសៀមរាប។

- ក្នុងការអនុវត្តកិច្ចការចាំបាច់ទាំងនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ខិតខំធ្វើការសម្របសម្រួលជាមួយប្រជាពលរដ្ឋពាក់ព័ន្ធ ដោយប្រកាន់ខ្ជាប់គោលការណ៍សិទ្ធិមនុស្ស និងមនុស្សធម៌ឱ្យបានជាអតិបរមា ក្នុងនោះបានធ្វើការប្រជុំជាច្រើនលើកច្រើនសា ដើម្បីផ្សព្វផ្សាយ និងពន្យល់អំពីកិច្ចចាំបាច់នេះរបស់រាជរដ្ឋាភិបាល ជូនដល់ប្រជាពលរដ្ឋ ដែលភាគច្រើនលើសលប់មានអំណរសាទរ និងសេចក្តីរីករាយក្នុងការទទួលយកដំណោះស្រាយរបស់រាជរដ្ឋាភិបាល។

៣- Please provide information on the measures taken to clearly identify the 113 "traditional villages", and any private or community-owned land, which should not be subjected to evictions, and to provide these individuals including Indigenous Peoples with legal security of tenure. In addition, please indicate how has your Excellency's Government endeavored to ensure that all people living in Angkor can enjoy a certain degree of security of tenure.

- ក្រោយអង្គរត្រូវបានចុះបញ្ជីជាបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ១៩៩២ នៅឆ្នាំ២០០៤ អាជ្ញាធរជាតិអប្សរាបានធ្វើជំរឿនប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិទាំងអស់ ស្ថិតក្នុងតំបន់រមណីយដ្ឋានអង្គរ ដើម្បីជាមូលដ្ឋានគោលសម្រាប់ការរៀបចំគ្រប់គ្រងរមណីយដ្ឋាន និងវិធានការគាំពារដល់អ្នកស្រុកអង្គរ។ ប្រជាពលរដ្ឋដែលស្ថិតក្នុងបញ្ជីឆ្នាំ២០០៤ ត្រូវចាត់ទុកថាជាប្រជាពលរដ្ឋដែលតាំងទីលំនៅស្របច្បាប់ និងត្រូវបានផ្តល់ការការពារពេញលេញ ព្រមទាំងជំនួយផ្សេងៗពីរដ្ឋ ក្នុងការចូលរួមចំណែកក្នុងការការពារសម្បត្តិបេតិកភណ្ឌមនុស្សជាតិ។ បច្ចុប្បន្ន ចំនួនប្រជាពលរដ្ឋដែលបានចូលទៅតាំងទីលំនៅលក្ខណៈមិនរៀបរយក្នុងតំបន់ការពារបេតិកភណ្ឌដោយគ្មានហេដ្ឋារចនាសម្ព័ន្ធគាំទ្រសមស្របសម្រាប់ការរស់នៅ បានកើនឡើងយ៉ាងខ្លាំង ក្លាយជាសម្ពាធធ្ងន់ធ្ងរដល់ប្រាសាទបុរាណ និងបរិស្ថានជុំវិញគួរឱ្យព្រួយបារម្ភ។ ដោយហេតុថា ប្រជាពលរដ្ឋទាំងនោះពុំមានកម្មសិទ្ធិដីធ្លីស្របច្បាប់ ពុំអាចទទួលបាននូវសេវាទឹកស្អាត អគ្គិសនី ផ្លូវ ប្រព័ន្ធបង្ហូរទឹកកខ្វក់ មន្ទីរពេទ្យ និងសាលារៀន រាជរដ្ឋាភិបាលមានភាពចាំបាច់ត្រូវរកដំណោះស្រាយសមស្របជាបន្ទាន់។
- រាជរដ្ឋាភិបាល បានផ្តល់ជូនគ្រួសារស្ម័គ្រចិត្តតាំងទីលំនៅថ្មីនូវដីឡូតិ៍ចំនួន ៥ ៨៦៥ នៅក្រុងរុនតាឯកតេជោសែន និងចំនួន ៤ ០៣៩ នៅតំបន់អភិវឌ្ឍន៍ពាក់ស្នែងក៏ដោយ ក៏ប៉ុន្តែចំនួននេះ អាចដោះស្រាយបានត្រឹមចំនួន ៩ ៩០៤ គ្រួសារ នៃប្រជាពលរដ្ឋដែលកំពុងតាំងទីលំនៅខុសច្បាប់នៅក្នុងតំបន់រមណីយដ្ឋានអង្គរប៉ុណ្ណោះ ក៏នៅមានគ្រួសារប្រជាពលរដ្ឋមួយចំនួនទៀតដែលរាជរដ្ឋាភិបាលត្រូវបន្តគិតគូរដោះស្រាយ។
- អ្នកស្រុកអង្គរ មិនមែនជាជនជាតិដើមភាគតិចនោះឡើយ គឺជាប្រជាពលរដ្ឋកម្ពុជាដែលបានរស់យូរលង់នៅក្នុងតំបន់ឧទ្យានបុរាណអង្គរមុនឆ្នាំ២០០៤ ហើយពួកគេត្រូវបានចាត់ទុកថាជាផ្នែកមួយនៃបេតិកភណ្ឌរស់ ជាព្រលឹងនៃប្រាសាទដែលត្រូវបានទទួលជំនួយឧបត្ថម្ភ និងការលើកទឹកចិត្តពីរដ្ឋ។

៤- Please provide information on the measures that your Excellency's Government is undertaking to protect the communities living in Angkor from forced evictions and arbitrary displacement; and to ensure that any decision affecting Indigenous Peoples'

lands, territories and resources is taken only with their free, prior and informed consent.

- រាជរដ្ឋាភិបាលបានដាក់ចេញនូវច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនក្នុងនោះរួមមានដូចជា ព្រះរាជក្រឹត្យលេខ ០០១ ន.ស. ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាបអង្គរ និងសេចក្តីសម្រេចលេខ ៧០ សសរ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការកំណត់បទដ្ឋាននៃការប្រើប្រាស់ដីតំបន់១ និងតំបន់២ ក្នុងតំបន់រមណីយដ្ឋានសៀមរាបអង្គរ ជាដើម ស្របតាមច្បាប់ជាធរមាន ជាពិសេសរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់កំពូលរបស់ជាតិ។ តាមរយៈលិខិតបទដ្ឋានទាំងនេះ សិទ្ធិរបស់អ្នកស្រុកអង្គរ ត្រូវបានការពារ ជាអាទិ៍÷
  - ប្រជាពលរដ្ឋដែលមានលំនៅដ្ឋាន និងរស់នៅយូរលង់មកហើយ អាចបន្តរស់នៅតទៅទៀតបាន ដោយមិនមានការដេញឱ្យចាកចេញពីភូមិឋានឡើយ។
  - ប្រជាពលរដ្ឋមានសិទ្ធិរុះរើជួសជុលផ្ទះចាស់ទ្រុឌទ្រោម ឬសាងសង់ថ្មីជំនួសផ្ទះចាស់បាន ដោយមានការសុំអនុញ្ញាតពីសមត្ថកិច្ចនៃអាជ្ញាធរជាតិអប្សរា។
  - ប្រជាពលរដ្ឋមានសិទ្ធិគ្រប់គ្រង និងចាត់ចែងដីធ្លីតាមរូបភាពដូចជា ផ្ទេរមរតកទៅឱ្យញាតិសន្តាន ពីឪពុកម្តាយទៅកូនក្មួយ ឬលក់ដូរឱ្យអ្នកភូមិផងជាមួយគ្នា ដើម្បីដោះស្រាយជីវភាព ប៉ុន្តែហាមឃាត់សកម្មភាពទិញ-លក់ដីរបស់ឈ្មួញ ក្នុងគោលដៅធ្វើអាជីវកម្មយកចំណេញសម្រាប់ក្រុមហ៊ុន ឬបុគ្គល ឬការទិញ-លក់ដីសម្រាប់យកទៅសាងសង់សណ្ឋាគារ ភោជនីយដ្ឋាន កន្លែងកំសាន្ត ជាដើម។ល។
  - ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់អង្គរទទួលបានសិទ្ធិការងារមុនគេក្នុងការចូលរួមអភិរក្ស និងជួសជុលប្រាសាទ ព្រមទាំងទទួលនូវការបណ្តុះបណ្តាលវិជ្ជាជីវៈទាក់ទងនឹងការងារអភិរក្ស និងគ្រប់គ្រងរមណីយដ្ឋានអង្គរ
  - រដ្ឋពិនិត្យលទ្ធភាពបង្កើតនូវសហគមន៍ទេសចរណ៍ ដើម្បីផ្តល់លទ្ធភាពឱ្យប្រជាជនមូលដ្ឋានទទួលបាននូវលទ្ធភាពក្នុងការបង្កើតប្រាក់ចំណូលប្រចាំថ្ងៃពីវិស័យទេសចរណ៍
  - ជំរុញការរៀបចំចងក្រងជាសហគមន៍វប្បធម៌នៅតាមភូមិឋាន ដើម្បីថែរក្សា និងដឹងជាប្រពៃណីពីដូនតាដល់កូនចៅ សហគមន៍ជំនាន់ក្រោយបន្តបន្ទាប់
  - លើកស្ទួយតម្លៃទេសភាពតាមរយៈការរៀបចំដែនដី ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងផែនការអភិរក្សធម្មជាតិនៅក្នុងតំបន់ការពារបេតិកភណ្ឌអង្គរ។

៥- Please indicate whether all people threatened with or already subjected to forced resettlement have been meaningfully consulted, have had the possibility to propose alternatives to resettlement, to participate in the selection of the resettlement sites, in defining adequate compensation including replacement land, as well as integration measures. Please also indicate how your Excellency's Government has obtained the free, prior and informed consent of the Indigenous Peoples for the resettlement plan.

- ប្រជាពលរដ្ឋដែលស្ថិតក្នុងបញ្ជីជំរឿនឆ្នាំ២០០៤ មិនមែនជាកម្មវត្ថុនៃការធ្វើការផ្លាស់ប្តូរទីលំនៅទេ លើកលែងតែពួកគាត់ធ្វើការស្នើសុំ ដើម្បីទទួលបានលំនៅឋានថ្មី ដែលមានកម្មសិទ្ធិដីធ្លីនិងផ្ទះសម្បែងពេញលេញនៅក្នុងក្រុងរុនតាឯកតេជោសែន និងតំបន់អភិវឌ្ឍន៍ពាក់ស្នែង ក៏រាជរដ្ឋាភិបាលនៅតែទទួលយកសំណើនិងធ្វើការសម្របសម្រួលផ្តល់ជូនពួកគាត់ តាមគោលការណ៍មនុស្សធម៌ដែរ។ ដោយឡែក ជនដែលចូលទៅតាំងទីលំនៅក្នុងតំបន់ការពារឧទ្យានអង្គរដោយខុសច្បាប់ ពុំមានកម្មសិទ្ធិលើដីធ្លី ឬអគារណាមួយឡើយ ភាគច្រើនពួកគេតាំងទីលំនៅដោយខ្ទម ឬតូប របៀបជាតំបន់អនាធិបតេយ្យ គ្មានសុវត្ថិភាព និងផាសុកភាពឡើយ ដូច្នេះ ពួកគេរីករាយហើយស្ម័គ្រចិត្តទទួលយកដំណោះស្រាយផ្តល់ជូនដោយរាជរដ្ឋាភិបាល។

៦- Please provide information on the efforts that your Excellency's Government is undertaking to ensure that the resettled communities resume and continue enjoying access to adequate housing, food, land for food production, safe drinking water and sanitation, and other means of livelihood.

- រាជរដ្ឋាភិបាល នឹងបន្តខិតខំអនុវត្តការងារនានា ទៅតាមលំដាប់អាទិភាពជាបន្តបន្ទាប់ ជាអាទិ៍÷
  - បន្តជំរុញឱ្យក្រសួងស្ថាប័នពាក់ព័ន្ធ កំណត់យកកិច្ចការទាំងនេះជាអាទិភាពខ្ពស់បំផុតរបស់ខ្លួន ដើម្បីធានាថាសាលារៀន មណ្ឌលសុខភាព និងសំណង់សាធារណៈផ្សេងៗទៀតក្នុងតំបន់ថ្មីនេះ មានសម្ភារបរិក្ខារ បុគ្គលិក មន្ត្រីបម្រើសេវាសាធារណៈគ្រប់គ្រាន់ និងប្រកបដោយទំនុកចិត្ត
  - បន្តលើកទឹកចិត្តប្រជាពលរដ្ឋបានចាប់ឆ្នោតរួច ដែលមិនទាន់ចាកចេញឱ្យផ្លាស់ប្តូរមកកាន់ទីលំនៅថ្មីក្នុងតំបន់អភិវឌ្ឍទាំងពីរនេះឱ្យបានទាន់ពេល ហើយអាជ្ញាធរត្រូវធ្វើការទប់ស្កាត់មិនឱ្យមានការចូលទន្ទ្រានជាថ្មីលើតំបន់ដែលបានផ្លាស់ប្តូរទីលំនៅចេញរួចហើយ
  - លើកទឹកចិត្តឱ្យវិស័យឯកជនមកតាំងមូលដ្ឋានអាជីវកម្ម ផលិតកម្ម សេវាកម្ម នៅក្នុងនិងក្បែរតំបន់អភិវឌ្ឍន៍ទាំងពីរនេះ ដើម្បីបង្កើតឱកាសការងារ និងមុខរបរបន្ថែមជូនប្រជាពលរដ្ឋក្នុងតំបន់ទាំងពីរ និងប្រែក្លាយតំបន់អភិវឌ្ឍន៍ទាំងពីរជាកូនទីក្រុងរណប ដែលមានសកម្មភាពសេដ្ឋកិច្ចរស់រវើក និងអាចទាញយកប្រយោជន៍ជាអតិបរមាពីសក្តានុពលសេដ្ឋកិច្ច នៃវិស័យទេសចរណ៍ ដែលកើតចេញពីរមណីយដ្ឋានអង្គរ និងប្រាសាទបុរាណនានា និងគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវ តំបន់សេដ្ឋកិច្ច បុរី លំនៅឋាន និងអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ ជាដើម
  - ជំរុញការចុះបញ្ជីដីធ្លី និងចេញបណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ ក្នុងតំបន់ទាំងពីរនេះ ជាអាទិភាពខ្ពស់បំផុត ដើម្បីធានាសុវត្ថិភាពនៃការកាន់កាប់ ប្រើប្រាស់អចលនវត្ថុ ប្រកបដោយទំនុកចិត្ត និងស្របច្បាប់ និងឱកាសកសាងសេដ្ឋកិច្ចគ្រួសារល្អប្រសើរជាងមុន
  - លើកកម្ពស់ការអភិវឌ្ឍក្រុងរុនតាឯកតេជោសែន និងតំបន់ពាក់ស្នែងបន្ថែមទៀត ដោយគិតគូរជាកញ្ចប់គ្រប់ជ្រុងជ្រោយ ទាំងការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ហេដ្ឋារចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ច ទាំងសេវាសាធារណៈ ឱ្យមានប្រសិទ្ធភាព និងភាពប្រទាក់ក្រឡាគ្នា ដើម្បីប្រែក្លាយទៅជាតំបន់គំរូ នៃការអនុវត្តគម្រោងសម្បទានដីសង្គមកិច្ចរបស់រដ្ឋឱ្យទៅជា "**បុរីជនបទសហសម័យទី១ នៅកម្ពុជា**"។

៧- Please indicate the steps that your Excellency's Government has taken to ensure that relocation complies with international human rights standards, as requested in decision 46 COM 7B.31 issued during the 46th session of the World Heritage Committee. Additionally, please indicate whether your Excellency's Government has invited a Reactive Monitoring Mission to assess among other things the conditions of the relocated communities, as required under the decision, and provide information on the Reactive Monitoring Mission's scope and possible dates.

- អាជ្ញាធរកម្ពុជាពុំបានអនុវត្តវិធានការបង្ខិតបង្ខំ ដើម្បីឱ្យប្រជាពលរដ្ឋចាកចេញពីរមណីយដ្ឋានអង្គរឡើយ ក្រៅពីគោលការណ៍ស្ម័គ្រចិត្តនោះទេ។ ព័ត៌មានអវិជ្ជមានមួយចំនួន ដែលកើតចេញពីការអនុវត្តវិធានការណ៍របស់អាជ្ញាធរកម្ពុជា ទៅលើជនអនាធិបតេយ្យ ដែលចូលកាន់កាប់ដី និងតាំងទីលំនៅខុសច្បាប់ ក្នុងតំបន់រមណីយដ្ឋានអង្គរ គឺជាវិធានការណ៍ធម្មតាដែលតែងតែអនុវត្តដោយអាជ្ញាធរមានសមត្ថកិច្ចនៅគ្រប់ប្រទេសលើសកលលោក។
- អាជ្ញាធរកម្ពុជា ស្វាគមន៍គ្រប់ភាគីទាំងអស់ រួមទាំងស្ថាប័នអន្តរជាតិ ដែលមានបំណងលើកកម្ពស់ការពារសម្បត្តិបេតិកភណ្ឌអង្គរ និងលើកកម្ពស់ការគោរពសិទ្ធិមនុស្ស ចូលរួមជាមួយដំណើរការដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងអនុវត្ត ដើម្បីរៀបចំកែលម្អលំនៅឋាន ហេដ្ឋារចនាសម្ព័ន្ធ សេវាសាធារណៈនិងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្រុងរុនតាឯកតេជោសែន និងតំបន់អភិវឌ្ឍន៍ពាក់ស្នែង ក៏ដូចជានៅទូទាំងប្រទេស សំដៅសម្រេចបានចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ប្រែក្លាយភូមិឋានទាំងអស់ ទៅជាភូមិឋានក្សេមក្សាន្តប្រកបដោយសុខសន្តិភាព សុវត្ថិភាព ចីរភាព សុខដុមរមនាសង្គម និងសុភមង្គលក្នុងក្រុមគ្រួសារ។

៨- Please indicate what measures have been taken to ensure that persons, including Indigenous Peoples, who have lost their housing, land, property, means for food production or livelihoods, or who have suffered any economic or cultural effect as a result of the forced evictions, arbitrary displacement and forced resettlement, have access to effective remedy and reparation.

សូមមេត្តាពិនិត្យចម្លើយក្នុងសំណួរទី៦ ខាងលើ។

៩- Please clarify what measures have been taken or are envisaged to provide protection and assistance to those displaced in Angkor, including the steps taken to ensure access to justice for victims and accountability for perpetrators of arbitrary displacement and attacks on displaced persons. Also, please provide information on any steps taken to enable durable solutions to their displacement.

សូមមេត្តាពិនិត្យចម្លើយក្នុងសំណួរទី៧ ខាងលើ។